# គាថាទី ១ [(១)]

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងដែនអាឡវី ទ្រង់ប្រារព្ធនូវឧបាសកម្នាក់ ទើបត្រាស់នូវព្រះគាថានេះថា

**ជិឃច្ឆា បរមា រោគា**
**សង្ខារា បរមា ទុក្ខា**
**ឯតំ ញត្វា យថាភូតំ**
**និព្វានំ បរមំ សុខំ ។**

សេចក្ដីស្រេកឃ្លាន ជារោគយ៉ាងក្រៃលែង សង្ខារទាំងឡាយ ជាទុក្ខយ៉ាងក្រៃលែង (អ្នកប្រាជ្ញ) ដឹងច្បាស់សេចក្ដីនុ៎ះ តាមពិតហើយ (រមែងធ្វើឱ្យជាក់ច្បាស់) នូវព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ។

---

១-បើរាប់តាមលំដាប់ក្នុងសុខវគ្គ ត្រូវជាគាថា ទី ៥

# កំណាព្យបឆភាភគតិ

សេចក្ដីស្រេកឃ្លាន ជារោគចំណាន លើសរោគទាំងឡាយ
តែងឈឺជានិច្ច ឥតជាដាច់ឡើយ ព្យាបាលពុំស្បើយ
លុះថ្ងៃមរណា ។

សង្ខារទាំងឡាយ លោកអធិប្បាយ ថាខន្ធមារ
ជាទុក្ខដ៏ឆ្នើម លើសទុក្ខនានា ដោយការរក្សា
ហៅខន្ធភារៈ ។

បុគ្គលបណ្ឌិត មានប្រាជ្ញាពិត ពិនិត្យឃើញជាក់
លោកមិនស្ទាក់ស្ទើរ តែងបានប្រចក្ស និព្វានសច្ចៈ
ជាសុខក្រៃលែង ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវព្រះរាជាព្រះនាម ព្រះបាទបសេនទិកោសល ទើបត្រាស់នូវព្រះគាថានេះថា

**អារោគ្យបរមា លាភា សន្តុដ្ឋិបរមំ ធនំ**
**វិស្សាសបរមា ញាតី និព្វានំ បរមំ សុខំ ។**

លាភមានការមិនមានរោគ ជាយ៉ាងក្រៃលែង ទ្រព្យមានសេចក្តីសន្តោស ជាយ៉ាងក្រៃលែង ញាតិមានសេចក្តីស្និទ្ធស្នាល ជាយ៉ាងក្រៃលែង ព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ។

# កំណាព្យបទព្រហ្មគីតិ

រីការមិនមានរោគ    ព្រះមានជោគទ្រង់សរសើរ
ចាត់ជាលាភប្រសើរ    គ្មានអ្វីស្មើលាភនេះបាន ។
ឯការចេះសន្ដោស    មិនល្មោភហួសទ្រព្យខ្លួនមាន
ត្រេកអរតាមមានបាន    ចាត់ជាទ្រព្យដ៏អស្ចារ្យ ។
ចំណែកក្រុមញាតិផៅ    ធ្លាប់រស់នៅជុំគ្រួសារ
មានក្ដីស្និទ្ធស្នាលគ្នា    ជាមេត្រីដ៏ក្រៃលែង ។
ចំពោះព្រះនិព្វាន    គឺជាឋានគួរស្ងប់ស្ងែង
ជាទីគ្មានភ្លើងផ្សេង    ក្រៃលែងដោយសេចក្ដីសុខ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ៣

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងនគរវេសាលី ទ្រង់ប្រារព្ធនូវព្រះតិស្សត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**បវិវេករសំ បិត្វា　　　　រសំ ឧបសមស្ស ច**

**និទ្ទរោ ហោតិ និប្បាបោ　ធម្មប្បីតិរសំ បិវំ ។**

ភិក្ខុផឹករសវិវេកផង រសព្រះនិព្វាន ជាទីរម្ងាប់កិលេសផង ផឹករសបីតិដែលកើតអំពីធម៌ផង ទើបជាអ្នកមិនមានសេចក្តីក្រវល់ក្រវាយ មិនមានសេចក្តីសៅហ្មងឡើយ ។

# កំណាព្យបទពាក្យ ៧

ភិក្ខុកាលផឹករសវិវេក ត្រជាក់ពន់ពេកក្នុងសន្ដាន

ព្រមទាំងបានផឹករសនិព្វាន ជាស្ថានពុំមានកិលេសជិត ។

ឬផឹកបីតិគួរត្រេកអរ កើតអំពីធម៌ល្អប្រណិត

ទើបបានជាអ្នកមានសុខពិត ក្នុងចិត្តឥតក្ដីសៅហ្មងឡើយ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ៤

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវេឡុវគ្រាម ទ្រង់ប្រារព្ធនូវសក្កទេវរាជ ទើបត្រាស់នូវព្រះគាថានេះថា

សាធុ ទស្សនមរិយានំ សន្និវាសោ សទា សុខោ
អទស្សនេន ពាលានំ និច្ចមេវ សុខី សិយា ។
ពាលសង្គតចារី ហិ ទីឃមទ្ធាន សោចតិ
ទុក្ខោ ពាលេហិ សំវាសោ អមិត្តេនេវ សព្វទា ។
ធីរោ ច សុខសំវាសោ ញាតីនំវ សមាគមោ
តស្មា ហិ

ធីរញ្ច បញ្ញញ្ច ពហុស្សុតញ្ច
ធោរយ្ហសីលំ វតវន្តមរិយំ

**តំ តាទិសំ សប្បុរិសំ សុមេធំ**
**ភជេថ នក្ខត្តបថំវ ចន្ទិមា ។**

ការចួបប្រទះ ព្រះអរិយបុគ្គលទាំងឡាយ ជាការល្អ ការនៅរួមជាមួយព្រះអរិយបុគ្គលទាំងឡាយ ជាហេតុឱ្យកើតសេចក្ដីសុខសព្វកាល បុគ្គលគប្បីមានសេចក្ដីសុខអស់កាលជានិច្ចបាន ព្រោះមិនចួបប្រទះបុគ្គលពាលទាំងឡាយ ។

បុគ្គលអ្នកប្រព្រឹត្ត សមគប់ដោយជនពាល រមែងសោកស្ដាយអស់កាលយូរអង្វែង ការនៅរួមជាមួយនឹងជនពាល រមែងជាទុក្ខសព្វកាល ។ ដូចការនៅរួមជាមួយនឹងសត្រូវ ចំណែកខាងការនៅរួមនឹងធីរជន រមែងជាសុខ ដូចការចួបជុំនៃញាតិទាំងឡាយ

ព្រោះហេតុនោះឯង

បុគ្គលគួរសេពគប់សប្បុរស ជាអ្នកមាំមួនផង មានបញ្ញាផង មានសេចក្តីចេះដឹងច្រើនផង មានកិរិយានាំទៅនូវធុរៈជាប្រក្រតីផង មានសីលវ័តនិងធុតង្គវត្តផង ជាអ្នកឆ្ងាយចាក កិលេសផង មានបញ្ញាល្អផង ប្រាកដដូច្នោះ ៗ ឱ្យដូចព្រះចន្ទគប់នូវផ្លូវនក្ខត្តឫក្ស ។

# កំណាព្យបទពាក្យ ៧

ការបាននៅរួមឬបានចួប បានគប់ប្រសព្វព្រះអរិយៈ
ជាហេតុឱ្យបានសុខឥតអាក់ ចិន្តាត្រជាក់សព្វ ៗ កាល ។
បុគ្គលមិនគួរមានក្តីទុក្ខ គួរមានក្តីសុខទុក្ខស្រយាល
សុខនេះកើតពីហេតុបណ្តាល មិនចួបជនពាលផងទាំងឡាយ ។
បុគ្គលនៅរួមដោយជនពាល រមែងរោលរាលនិងសោកស្តាយ
ខូចខ្លួនអស់កាលវែងអន្លាយ មិនចង់សោកស្តាយកុំនៅជិត ។
ការដែលនៅរួមដោយជនពាល ដូចកាលនៅរួមនឹងអមិត្ត
ចំណែកការនៅរួមបណ្ឌិត បីដូចនៅជិតញាតិទាំងឡាយ ។
ដូច្នេះគួរគប់សប្បុរស អ្នកមានចិត្តខ្ពស់មិនរាយមាយ

ជាអ្នកមាំមួនមានប្រាជ្ញប្រាយ  បញ្ញាទូលាយមិនទើសទាក់ ។
ព្រមទាំងជាអ្នកចេះដឹងច្រើន  ក្រវើនក្រតើនដោយធុរៈ
មានសីលគុណធុតង្គៈ  ជាអ្នកឆ្ងាយចាកកិលេសផង ។
បុគ្គលដែលបានធ្វើដូច្នោះ  នឹងរួចពីគ្រោះដ៏សៅហ្មង
ប្រៀបដូចចន្ទ្រារះម្តង ៗ  គប់រកគន្លងនក្ខត្តឫក្ស ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ៥[១]

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវបព្វជិតទាំងឡាយ ៣ រូប ទើបត្រាស់នូវព្រះគាថានេះថា

**អយោគេ យុញ្ជមត្តានំ យោគស្មិញ្ច អយោជយំ**
**អត្ថំ ហិត្វា បិយគ្គាហី បិហេតត្តានុយោគិនំ ។**
**មា បិយេហិ សមាគញ្ឆិ អប្បិយេហិ កុទាចនំ**
**បិយានំ អទស្សនំ ទុក្ខំ អប្បិយានញ្ច ទស្សនំ ។**

---

១-បើរាប់តាមលំដាប់ក្នុងបិយវគ្គ ត្រូវជាគាថា ទី ១

តស្មា បិយំ ន កយិរាថ បិយាបាយោ ហិ បាបកោ

គន្ថា តេសំ ន វិជ្ជន្តិ យេសំ នត្ថិ បិយាប្បិយំ ។

បុគ្គលកាលប្រកបខ្លួនទុក ក្នុងអំពើដែលមិនគួរប្រកប មិនប្រកបខ្លួនក្នុងអំពើដែលគួរប្រកប លះបង់ប្រយោជន៍ចេញហើយ កាន់យកតាមគាប់ចិត្ត រមែងស្រឡាញ់ បុគ្គលអ្នកប្រកបតាមខ្លួន ។

កុំគប់រកសត្វនិងសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ក្នុងកាលណា ៗ ឡើយ ព្រោះថា ការមិនចួបប្រសព្វសត្វនិងសង្ខារជាទី

ស្រឡាញ់ក្តី ការចួបប្រសព្វសត្វនិងសង្ខារមិនជាទីស្រលាញ់ក្តី ជាហេតុនាំមកនូវទុក្ខ ។

ព្រោះហេតុនោះ បុគ្គលមិនគួរធ្វើសត្វនិងសង្ខារឱ្យជាទីស្រឡាញ់ ព្រោះការព្រាត់ប្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ ជាសភាពអាក្រក់ ការស្រឡាញ់និងការស្អប់ មិនមានដល់ពួកជនណា កិលេសគ្រឿងចាក់ស្រែះទាំងឡាយ តែងមិនមានដល់ពួកជននោះ ។

# កំណាព្យបទភាគគតិ

គ្មានចិត្តមាំមួន តែងបណ្តោយខ្លួន តាមតែតណ្ហា
ល្អមិនប្រកប ជាប់អគោចរា លះសីលសិក្ខា
ស្រវាកាមគុណ ។
សត្វនិងសង្ខារ ជាទីប្រាថ្នា តែងបរាជន
ឱ្យមានក្តីសោក អនេកអនន្ត ព្រោះជាដើមទុន
នៃការសោកស្តាយ ។
វត្ថុសំអប់ កាលបើប្រសព្វ នឹងក្តៅក្រហាយ
គ្រប់ពេលបានជួប ចិត្តមិនសប្បាយ ក្រហល់ក្រហាយ
កើតព្យេរវេរា ។

~ ១៦ ~

ដូច្នោះបុគ្គល មិនគួររវល់ ដោយក្ដីប្រាថ្នា មិនគួរថ្នាំងថ្នាក់ ដោយចិត្តទោសា ទើបអាចកាប់ឆ្ការ កិលេសចេញបាន ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ៦

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុមួយរូប ទើបត្រាស់នូវព្រះគាថានេះថា

**បិយតោ ជាយតី សោកោ បិយតោ ជាយតី ភយំ**
**បិយតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។**

សេចក្ដីសោកកើតអំពីសេចក្ដីស្រឡាញ់ ភ័យកើតអំពីសេចក្ដីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្ដីស្រឡាញ់ហើយ សេចក្ដីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។

# កំណាព្យបទព្រហ្មគីតិពិសេស

វីភ័យនិងក្តីសោក    តែងកើតមកពីស្រឡាញ់
ស្រទន់ស្រពោនក្នាញ់    ព្រោះស្រឡាញ់ពេញចិន្តា ។
បើស្រឡាញ់មិនមាន    ក្នុងសន្តានស្ងប់បិយា
ភ័យសោកកើតពីណា    ក្នុងចិន្តាត្រូវតែស្បើយ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ៧

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវឧបាសិកាឈ្មោះវិសាខា ទើបត្រាស់នូវព្រះគាថានេះថា

**បេមតោ ជាយតី សោកោ បេមតោ ជាយតី ភយំ**
**បេមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។**

សេចក្ដីសោកកើតអំពីសេចក្ដីស្រឡាញ់ ភ័យកើតអំពីសេចក្ដីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្ដីស្រឡាញ់ហើយ សេចក្ដីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។

# កំណាព្យបទពាក្យ ៧

សេចក្តីភ័យព្រួយនិងក្តីសោក
រមែងកើតមកពីស្រឡាញ់
បើស្រឡាញ់ខ្លាំងកើតចិត្តក្តាញ់
ហួងហែងកំណាញ់កើតវេរា ។
បើការស្រឡាញ់មិនមានហើយ
ចិត្តស្ងប់ព្រងើយក្នុងសង្ខារ
សេចក្តីភ័យខ្លាចនិងសោកា
មានមកពីណាព្រោះអស់ហេតុ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ៨

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង កូដាគារសាលា នានគរវេសាលី ទ្រង់ប្រារព្ធនូវស្ដេច លិច្ឆវីទាំងឡាយ ទើបត្រាស់នូវព្រះគាថានេះថា

**រតិយា ជាយតី សោកោ   រតិយា ជាយតី ភយំ**

**រតិយា វិប្បមុត្តស្ស   នត្ថិ សោកោ កុតោ ភយំ ។**

សេចក្ដីសោកកើតអំពីតម្រេក ភ័យកើតអំពី តម្រេក កាលបើរួចស្រឡះចាកតម្រេកហើយ សេចក្ដី សោកក៏លែងមាន ភ័យនឹងមានមកពីណា ។

# កំណាព្យបទពាក្យ ៧

តម្រេកត្រេកអរក្នុងកាមា
នាំកើតសោកាក្នុងលោកីយ៍
ព្រមទាំងជាហេតុនៃទុក្ខភ័យ
អាឡោះអាល័យឈឺខ្លោចផ្សា ។
ថាបើតម្រេកត្រេកត្រអាល
បានឃ្លាតស្រយាលពីចិន្តា
ភ័យនិងក្តីសោកមានពីណា
មានតែភ្លឺថ្លាអស់បារម្ភ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ៩

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវអនិត្ថិគន្ធកុមារ ទើបត្រាស់នូវព្រះគាថានេះថា

**កាមតោ ជាយតី សោកោ   កាមតោ ជាយតី ភយំ**

**កាមតោ វិប្បមុត្តស្ស   នត្ថិ សោកោ កុតោ ភយំ ។**

សេចក្តីសោកកើតអំពីកាម ភ័យកើតអំពីកាម កាលបើរួចស្រឡះចាកកាមហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។

# កំណាព្យបទព្រហ្មគីតិ

វីសេចក្ដីសោយសោក    តែងកើតមកពីកាមា

ឯភ័យនោះសោតណា    ក៏មានកាមជាប្រភព ។

កាលបើចិត្តភ្លឺថ្លា    រួចកាមាដោយសព្វគ្រប់

ជីវិតលែងជំពប់    ការសោយសោកគ្មានទៀតឡើយ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ១០

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រាហ្មណ៏មួយរូប ទើបត្រាស់នូវព្រះគាថានេះថា

**តណ្ហាយ ជាយតី សោកោ តណ្ហាយ ជាយតី ភយំ**
**តណ្ហាយ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។**

សេចក្ដីសោកកើតអំពីតណ្ហា ភ័យកើតអំពីតណ្ហា កាលបើរួចស្រឡះចាកតណ្ហាហើយ សេចក្ដីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។

# កំណាព្យបទកាកគតិ

សោកក្តីភ័យក្តី ទាំងចាស់ទាំងថ្មី កើតពីតណ្ហា
តែងតែកើតមាន លើសត្វគ្រប់គ្នា ឥតមាននរណា
គេចវេះវាងបាន ។

បើចង់បានសុខ រួចចាកក្តីទុក្ខ ភ័យសោកសាមាន្យ
ត្រូវលះតណ្ហា ឱ្យខាងតែបាន នោះទើបសន្តាន
ក្សេមក្សាន្តទៅហោង ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ១១

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវទារកទាំងឡាយ មានប្រមាណ ៥០០ រូប ក្នុងចន្លោះនៃផ្លូវ ទើបត្រាស់នូវព្រះគាថានេះថា

**សីលទស្សនសម្បន្នំ ធម្មដ្ឋំ សច្ចវាទិនំ**

**អត្តនោ កម្មកុព្វានំ តញ្ជនោ កុរុតេ បិយំ ។**

ជនតែងធ្វើបុគ្គលដែលបរិបូណ៌ដោយសីល និងការឃើញត្រូវ ឋិតនៅក្នុងធម៌ ពោលសច្ចធម៌ជាប្រក្រតី ធ្វើកម្មជារបស់ខ្លួននោះ ឱ្យជាទីស្រឡាញ់ ។

# កំណាព្យបទភាគគតិ

បុគ្គលគួរធ្វើ ជនអ្នកប្រសើរ ដោយធមិកល្យាណ
ជាអ្នកមានសីល ជាប់ក្នុងសន្ដាន និងជាអ្នកមាន
ទិដ្ឋិត្រូវល្អ ។

ឬមួយជាអ្នក ពោលពាក្យសច្ចៈ ដោយចិត្តស្មោះស
អ្នកធ្វើការងារ តាមដោយគុណធមិ ឱ្យជាមិត្តល្អ
ជាទីស្រឡាញ់ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ១២

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះអនាគាមិត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**ឆន្ទជាតោ អនក្ខាតេ មនសា ច ផុដោ សិយា**
**កាមេ ច អប្បដិពទ្ធចិត្តោ ឧទ្ធំសោតោតិ វុច្ចតិ ។**

បុគ្គលអ្នកមានសេចក្ដីប្រាថ្នា ចំពោះព្រះនិព្វានដែលគេនិយាយប្រាប់គ្នាមិនបានផង ជាអ្នកមានមគ្គចិត្តនិងផលចិត្ត (ខាងក្រោម) ប៉ះពាល់ហើយផង មានចិត្តមិនប្រតិព័ទ្ធក្នុងកាមផង តថាគតហៅថា ជាអ្នកមានខ្សែមគ្គប្រព្រឹត្តទៅក្នុងខាងលើ ។

# កំណាព្យបទពាក្យ ៧

បុគ្គលប្រកបដោយបញ្ញា ជាអ្នកប្រាថ្នាព្រះនិព្វាន
មិនតែប៉ុណ្ណោះថែមទាំងមាន មគ្គចិត្តជាស្ពានដ៏ថ្លៃថ្លា ។
រួមដោយផលចិត្តទាំងបីកង ប៉ះពាល់ហើយផងគួរជ្រះថ្លា
ទាំងមិនប្រតិព័ទ្ធក្នុងកាមា ដែលព្រះតថាគតព្យាករណ៍ ។
ឱ្យឈ្មោះជននោះថាជាអ្នក មាននូវខ្សែមគ្គយ៉ាងបវរ
ប្រព្រឹត្តទៅក្នុងទីខ្ពស់ល្អ ដែលមនុស្សលោកក្រនឹងធ្វើបាន ។

ដោយឧបាសិកា *ឱម លក្ខណា*

# គាថាទី ១៣

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងព្រៃឈ្មោះឥសិបតនៈ ទ្រង់ប្រារព្ធនូវនន្ទិយកុលបុត្រ ទើបត្រាស់នូវព្រះគាថានេះថា

ចិរប្បវាសឹ បុរិសំ ទូរតោ សោត្ថិមាគតំ
ញាតី មិត្តា សុហជ្ជា ច អភិនន្ទន្តិ អាគតំ
តថេវ កតបុញ្ញម្បិ អស្មា លោកា បរំ គតំ
បុញ្ញានិ បដិគ្គណ្ហន្តិ បិយំ ញាតីវ អាគតំ ។

ពួកញាតិក្តី មិត្រក្តី សំឡាញ់ក្តី រមែងត្រេកអរនឹងបុរសដែលឃ្លាតគ្នាអស់កាលយូរ មកអំពីចម្ងាយដោយសួស្តី មកដល់ហើយ យ៉ាងណាមិញ បុណ្យទាំងឡាយ តែងទទួលបុគ្គល ដែលបានធ្វើបុណ្យ ច្យុតអំពីមនុស្សលោកនេះ ទៅកាន់លោកខាងមុខ ដូចញាតិទាំងឡាយ ទទួលបុរសជាទីស្រឡាញ់ទើបមកដល់ដូច្នោះឯង ។

# កំណាព្យបទព្រហ្មគីតិ

សម្លាញ់ឬសាច់ញាតិ ដែលបែកឃ្លាតគ្នាទៅឆ្ងាយ
ខានរួមសុខសប្បាយ ស្ដាយអាឡោះអាល័យគ្នា ។
ពេលញាតិឱ្យដំណឹង ថានឹងមកជួបភក្ត្រា
ត្រេកអរក្នុងចិន្តា ប្រាថ្នាជួបដោយរីករាយ ។
រីអ្នកសន្សំបុណ្យ ទានសីលសុន្ទរ៍ផងទាំងឡាយ
លុះបែកធ្លាយរាងកាយ ទម្លាយខន្ធចាប់ភពថ្មី ។
បុណ្យតែងចាំទទួល សម្រួលផ្លូវឱ្យសួស្ដី
ដូចពួកជនប្រុសស្រី ទទួលញាតិពីចម្ងាយ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ១៤[១]

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង និគ្រោធារាម ទ្រង់ប្រារព្ធនូវខត្តិយកញ្ញា ឈ្មោះនាង រោហិណី ទើបត្រាស់នូវព្រះគាថានេះថា

**កោធំ ជហេ វិប្បជហេយ្យ មានំ**
**សញ្ញោជនំ សព្វមតិក្កមេយ្យ**
**តន្នាមរូបស្មិ មសជ្ជមានំ**
**អកិញ្ចនំ នានុបតន្តិ ទុក្ខា ។**

---

១-បើរាប់តាមលំដាប់ក្នុងកោធវគ្គ ត្រូវជាគាថា ទី ១

បុគ្គលគួរលះបង់សេចក្ដីក្រោធចេញ គួរលះបង់មានះចេញ គួរកន្លងសញ្ញោជនធម៌ទាំងអស់ចោលចេញ ទុក្ខទាំងឡាយ តែងមិនជាប់តាមបុគ្គល ដែលមិនចំពាក់ក្នុងនាមនិងរូប មិនមានកិលេស គ្រឿងកង្វល់នោះឡើយ ។

# កំណាព្យបទពាក្យ ៧

បុគ្គលគួរលះសេចក្តីក្រោធ ការខឹងច្រឡោតខុសមាត្រា
គួរលះមានះធមិហឹនា សន្សំបញ្ញាបន្ទាបខ្លួន ។
គួរលះពួកធមិសំយោជនៈ កិលេសគ្រប់ថ្នាក់ឱ្យបានផ្ទួន
ដឹងថានាមរូបមិនមាំមួន មិនយកជាខ្លួនឬអាត្មា ។
នាទីអវសានបុគ្គលនោះ នឹងបានចាក់ធ្លុះអរិយសច្ចា
អស់ព្រួយរន្ធត់គ្រប់ប្រការ តែងមានចិន្តាស្ងប់រម្ងាប់ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ១៥

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្បែរចេតិយ ឈ្មោះអគ្គាឡវៈ ទ្រង់ប្រារព្ធនូវភិក្ខុមួយរូប ទើបត្រាស់នូវព្រះគាថានេះថា

**យោ វេ ឧប្បតិតំ កោធំ រថំ ភន្តំវ ធារយេ**
**តមហំ សារថឹ ព្រូមិ រស្មិគ្គាហោ ឥតរោ ជនោ។**

បុគ្គលណា ឃាត់សេចក្ដីក្រោធ ដែលកើតឡើងហើយ ដូចសារថី ទប់រថដែលកំពុងលឿនបាន តថាគតហៅបុគ្គលនោះថា ជាសារថី ជនក្រៅពីនេះ គ្រាន់តែជាអ្នកកាន់ខ្សែបរ ( មិនមែនសារថីឡើយ ) ។

# កំណាព្យបទពាក្យ ៧

បុគ្គលពូកែពិតប្រាកដ    គឺពិតសង្កត់ចិត្តក្រោធបាន
ដូចនាយសារថីដ៏ចំណាន  ជាអ្នកក្លាហានមានប្រាជ្ញា ។
សូម្បីរថលឿនហួសប្រមាណ ក៏អាចទប់បានតាមប្រាថ្នា
រីបុគ្គលនោះព្រះសាស្តា  ទ្រង់ត្រាស់ហៅថាសារថី ។
រីជនដទៃព្រះសាស្តា    មិនទ្រង់ហៅថាសារថី
គ្រាន់តែកាន់ខ្សែបរធ្វើ   បើមានការណ៍អ្វីតែងភាន់ភាំង ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ១៦

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវឧបាសិកាឈ្មោះឧត្តរា ទើប ត្រាស់នូវព្រះគាថានេះថា

**អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ**

**ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។**

បុគ្គលគប្បីផ្ចាញ់មនុស្សក្រោធ ដោយសេចក្តី មិនក្រោធ គប្បីផ្ចាញ់មនុស្សអសប្បុរស ដោយសប្បុរស គប្បីផ្ចាញ់មនុស្សកំណាញ់ ដោយការឱ្យ គប្បីផ្ចាញ់ មនុស្សនិយាយពាក្យមិនពិត ដោយពាក្យពិត ។

~ ៤០ ~

# កំណាព្យបទភាគគតិ

បុគ្គលគប្បី  យកធម៌ខន្តី  ផ្ចាញ់មនុស្សដែលក្រោធ

កាលខឹងក្តៅឆេះ ចេះទៅជាឆោត ផ្ចាញ់ដោយមិនក្រោធ

ឈ្នះគ្រប់បញ្ហា ។

វីរអសប្បុរស  មិនមានចិត្តស្មោះ ទទួលធម៌អាថ៌

គួរផ្ចាញ់ដោយចិត្ត អាណិតមេត្តា  ទាំងកាយវាចា

តបដោយភាពល្អ ។

ឯមនុស្សកំណាញ់ បុគ្គលគួរផ្ចាញ់  យកឈ្នះចិត្តក្រ

ដោយឱ្យទានញឹក ល្ងាចព្រឹកបន្ត  មច្ឆរិយៈក៏

គង់តែមរណា ។

វីមនុស្សកុហក ពោលពាក្យអាក្រក់ ឡេះឡោះមុសា

គួរផ្ចាញ់ដោយពាក្យ ពិតមានខ្លឹមសារ សច្ចវាចា

ឈ្នះរសទាំងពួង ។

ដោយឧបាសិកា *ឱម លក្ខណា*

# គាថាទី ១៧

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវបញ្ហារបស់ព្រះមហាមោ-គ្គល្លានត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**សច្ចំ ភណេ ន កុជ្ឈេយ្យ ទជ្ជា អប្បស្មិ យាចិតោ**
**ឯតេហិ តីហិ ឋានេហិ គច្ឆេ ទេវាន សន្តិកេ ។**

បុគ្គលគួរពោលពាក្យពិត ១ មិនគួរក្រោធ ១ កាលគេសូមវត្ថុសូម្បីមានតិច ក៏គួរឱ្យ (តាមតិច) ១ បុគ្គលគប្បីទៅកើត ក្នុងសំណាក់ទេវតាទាំងឡាយបាន ដោយហេតុទាំង ៣ នេះឯង ។

# កំណាព្យបទព្រហ្មគីតិ

បុគ្គលគួរគប្បី ពោលស្រដីតែពាក្យពិត
កុំពោលតាមតែគិត ត្រូវគិតសិនសឹមស្រដី ។
មិនគួរខឹងច្រឡោត ដោយចិត្តក្រោធខ្វះមេត្រី
ទប់ស្កាត់ចិត្តអប្រិយ ដោយខន្តីនិងមេត្តា ។
គួរតែចេះចែកទាន ទោះបីមានតិចម្ដេចណា
ឱ្យហើយមានចាគា មិនប្រាថ្នាផលតបស្នង ។
វិធមិទាំងបីនេះ ជាជំនិះល្អឥតហ្មង
លើសយានទាំងពួងផង អាចចម្លងទៅទេវលោក ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ១៨

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងអញ្ជនវនារាម ទ្រង់ប្រារព្ធនូវបញ្ហា ដែលភិក្ខុទាំងឡាយទូលសួរ ទើបត្រាស់នូវព្រះគាថានេះថា

**អហឹសកា យេ មុនយោ និច្ចំ កាយេន សំវុតា**

**តេ យន្តិ អច្ចុតំ ឋានំ យត្ថ គន្ត្វា ន សោចរេ ។**

ជនទាំងឡាយណា ជាអ្នកប្រាជ្ញ មិនបៀតបៀនសត្វដទៃ សង្រួមហើយដោយកាយទ្វារ (ជាដើម) ជានិច្ច ជនទាំងឡាយនោះ រមែងទៅកាន់ឋានដ៏មិនប្រែប្រួល ជាឋានដែលគេទៅដល់ហើយ តែងមិនសោកស្តាយ ។

# កំណាព្យបទពាក្យ ៧

ជនទាំងឡាយណាជាអ្នកប្រាជ្ញ
សន្តោសមិនកាចបៀតបៀនសត្វ
ព្យាយាមសង្រួមប្រុងប្រយ័ត្ន
ចិត្តកាយអណ្តាតរាល់វេលា ។
ជនទាំងឡាយនោះរមែងទៅ
កាន់ស្ថានដែលនៅហួសសួគ៌ា
ជាស្ថានអមតៈជនគ្រប់គ្នា
ស្គាល់ហើយធានាមិនសោកស្តាយ ។

ដោយឧបាសិកា ***ឱម លក្ខណា***

# គាថាទី ១៩

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទ្រង់ប្រារព្ធនូវនាងបុណ្ណាទាសី ទើបត្រាស់នូវព្រះគាថានេះថា

**សទា ជាគរមានានំ អហោរត្តានុសិក្ខិនំ**

**និព្វានំ អធិមុត្តានំ អត្ថំ គច្ឆន្តិ អាសវា ។**

អាសវៈទាំងឡាយរបស់បុគ្គល អ្នកភ្ញាក់រឭកសព្វកាល ជាអ្នកសិក្សាត្រៃសិក្ខា ទាំងថ្ងៃទាំងយប់ មានចិត្តចុះស៊ប់កាន់ព្រះនិព្វាន តែងដល់នូវការតាំងនៅមិនបានឡើយ ។

# កំណាព្យបទភាគគតិ

វីបុគ្គលណា ជាអ្នកឧស្សាហ៍ មិនភ្លេចស្មារតី
អ្នកភ្ញាក់រលឹក មិនថាយប់ថ្ងៃ ខិតខំសម្ដី
រៀនត្រៃសិក្ខា ។
មានចិត្តចុះកាន់ ស៊ប់ក្នុងនិព្វាន បរមសុខា
វីបុគ្គលនោះ ទ្រង់ត្រាស់ទុកថា ជាអ្នកភ្លឺថ្លា
អស់អាសវៈ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២០

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវអតុលឧបាសក ទើបត្រាស់ នូវព្រះគាថានេះថា

**បោរាណមេតំ អតុល　　នេតំ អជ្ជតនាមិវ**
**និន្ទន្តិ តុណ្ហិមាសីនំ　　និន្ទន្តិ ពហុភាណិនំ**
**មិតភាណិម្បិ និន្ទន្តិ　　នត្ថិ លោកេ អនិន្ទិតោ ។**
**ន ចាហុ ន ច ភវិស្សតិ　　ន ចេតរហិ វិជ្ជតិ**
**ឯកន្តំ និន្ទិតោ បោសោ　　ឯកន្តំ វា បសំសិតោ ។**

យញ្ចេ វិញ្ញូ បសំសន្តិ អនុវិច្ច សុវេ សុវេ
អច្ឆិទ្ទវុត្តឹ មេធាវឹ បញ្ញាសីលសមាហិតំ
នេក្ខំ ជម្ពោនទស្សេវ កោ តំ និន្ទិតុមរហតិ
ទេវាបិ នំ បសំសន្តិ ព្រហ្មុនាបិ បសំសិតោ ។

ម្នាលអតុលៈ ការតិះដៀលនិងការសរសើរនេះ ជារបស់បូរាណ ការតិះដៀលនិងការសរសើរនេះ មិនមែនទើបនឹងកើតឡើងក្នុងថ្ងៃនេះទេ (ព្រោះថា) ជនទាំងឡាយ តែងនិន្ទាបុគ្គលអ្នកអង្គុយស្ងៀមក៏មាន និន្ទាបុគ្គលអ្នកនិយាយច្រើនក៏មាន និន្ទាបុគ្គលអ្នកនិយាយល្មមប្រមាណក៏មាន (អ្នកណា ៗ ក៏ដោយ) ក្នុងលោក ដែលមិនត្រូវគេនិន្ទាគ្មានឡើយ ។

បុគ្គលដែលត្រូវគេនិន្ទាតែម្យ៉ាង ឬត្រូវគេសរសើរតែម្យ៉ាង មិនមែនមានមកហើយតែក្នុងអតីតទេ នឹងមានទៅក្នុងអនាគតក៏ទេ មានតែក្នុងបច្ចុប្បន្ននេះក៏ទេ ។

បើអ្នកប្រាជ្ញទាំងឡាយ សង្កេតមើលរាល់ ៧ ថ្ងៃ ហើយសរសើរបុគ្គលណា ដែលជាអ្នកប្រព្រឹត្តមិនដាច់ មានប្រាជ្ញា មានចិត្តតម្កល់ខ្ជាប់ ក្នុងបញ្ញានិងសីល អ្នកណាគួរនឹងនិន្ទាបុគ្គល ដែលដូចជាឆ្តោរនៃមាសជម្ពូនទនោះបាន សូម្បីទេវតានិងមនុស្សទាំងឡាយក៏សរសើរបុគ្គលនោះ ទាំងព្រហ្មក៏សរសើរ (ដូចគ្នា) ។

# កំណាព្យបទព្រហ្មគីតិ

នៃរើយអតុលៈ ដឹងឱ្យជាក់កុំសើៗ
និន្ទានិងសរសើរ មានដំណើរមកយូរហើយ ។
ចូរអ្នកកុំនឹកស្មាន ថាទើបមានថ្ងៃនេះឡើយ
លំអានមានយូរហើយ ចាត់ជាធម៌ពីបូរាណ ។
ទោះអ្នកគ្មានសំដី ឬនិយាយដឹងប្រមាណ
គង់គេនិន្ទាបាន គ្រប់ប្រាណតែងមានរាល់រូបា ។
បើពាលពោលសរសើរ កុំល្ងីល្ងើយកជាការ
បើប្រាជ្ញលោកស្តីថា ផ្សៀងសោតាស្តាប់យកចុះ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២១

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ ទើបត្រាស់នូវព្រះគាថានេះថា

កាយប្បកោបំ រក្ខេយ្យ កាយេន សំវុតោ សិយា
កាយទុច្ចរិតំ ហិត្វា កាយេន សុចរិតំ ចរេ
វចីបកោបំ រក្ខេយ្យ វាចាយ សំវុតោ សិយា
វចីទុច្ចរិតំ ហិត្វា វាចាយ សុចរិតំ ចរេ
មនោបកោបំ រក្ខេយ្យ មនសា សំវុតោ សិយា
មនោទុច្ចរិតំ ហិត្វា មនសា សុចរិតំ ចរេ

**កាយេន សំវុតា ធីរា អថោ វាចាយ សំវុតា**
**មនសា សំវុតា ធីរា តេ វេ សុបរិសំវុតា ។**

បុគ្គលគប្បីរក្សានូវការកម្រើកកាយ គប្បីសង្រួមកាយ គប្បីលះបង់កាយទុច្ចរិត គប្បីប្រព្រឹត្តកាយសុចរិត គប្បីរក្សានូវការកម្រើកវាចា គប្បីសង្រួមវាចា គប្បីលះបង់វចីទុច្ចរិត គប្បីប្រព្រឹត្តវចីសុចរិត គប្បីរក្សានូវការកម្រើកចិត្ត គប្បីសង្រួមចិត្ត គប្បីលះបង់មនោទុច្ចរិត គប្បីប្រព្រឹត្តមនោសុចរិត អ្នកប្រាជ្ញទាំងឡាយ បានសង្រួមកាយ សង្រួមវាចា អ្នកប្រាជ្ញទាំងឡាយ បានសង្រួមចិត្តហើយ លោកទាំងនោះឯង ឈ្មោះថា សង្រួមហើយដោយប្រពៃ ។

# កំណាព្យបទពាក្យ ៧

បុគ្គលគប្បីរក្សាកាយ ឱ្យស្ថិតនៅឆ្ងាយពីទុច្ចរិត
ឱ្យតាំងនៅក្នុងតែសុចរិត មិនត្រូវប្រព្រឹត្តអនាចារ ។
គប្បីរក្សាពាក្យសម្តី ឱ្យផុតអំពីពាក្យមុសា
សម្តីអាក្រក់ផងនានា ពោលតែវាចាល្អប្រពៃ ។
គប្បីសង្រួមផ្លូវចិត្តផង កុំឱ្យសៅហ្មងទាំងយប់ថ្ងៃ
គំនិតមិនល្អត្រូវកែខៃ រួសរាន់លកលៃគិតសុចរិត ។
បើបានសង្រួមកាយវាចា ទាំងចិត្តសោតណាឱ្យប្រណិត
ទាំងបីនេះឯងព្រះទ្រង់ឫទ្ធិ ទ្រង់ត្រាស់ថាពិតជាប្រពៃ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២២[(១)]

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវបុត្ររបស់អ្នកសម្លាប់គោម្នាក់ ទើបត្រាស់នូវព្រះគាថានេះថា

បណ្ឌុបលាសោវទានិសិ
យមបុរិសាបិ ច តេ ឧបដ្ឋិតា
ឧយ្យោគមុខេ ច តិដ្ឋសិ
បាថេយ្យម្បិ ច តេ ន វិជ្ជតិ ។
សោ ករោហិ ទីបមត្តនោ
ខិប្បំ វាយម បណ្ឌិតោ ភវ
និទ្ធន្តមលោ អនង្គណោ
ទិព្វំ អរិយភូមិមេហិសិ ។

---

១-បើរាប់តាមលំដាប់ក្នុងមលវគ្គវគ្គ ត្រូវជាគាថា ទី ១

ឥឡូវនេះ ខ្លួនអ្នកដូចស្លឹកឈើទុំហើយ ទាំងពួកបុរសរបស់យមរាជ ប្រាកដដល់អ្នកហើយ ខ្លួនអ្នកតាំងនៅក្នុងមាត់សេចក្ដីវិនាស សូម្បីស្បៀងគឺកុសលរបស់អ្នក ក៏មិនទាន់មានឡើយ ។

អ្នកចូរធ្វើកុសលជាទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឱ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក (ធ្វើយ៉ាងនេះហើយ) នឹងទៅជាអ្នកកម្ចាត់បង់មន្ទិលបាន មិនមានទីទួលគឺកិលេស នឹងដល់នូវភូមិរបស់ព្រះ-អរិយៈ ដូចជាទិព្វបាន ។

ឧបនីតវយោ វទានិសិ

សម្បយាតោសិ យមស្ស សន្តិកំ

វាសោបិ ច តេ នត្ថិ អន្តរា

បាថេយ្យម្បិ ច តេ ន វិជ្ជតិ ។

សោ ករោហិ ទីបមត្តនោ

ខិប្បំ វាយម បណ្ឌិតោ ភវ

និទ្ធន្តមលោ អនង្គណោ

ន បុន ជាតិជរំ ឧបេហិសិ ។

ឥឡូវនេះ ខ្លួនអ្នកត្រូវជរាចូលដល់ហើយ ជាអ្នករៀបដំណើរទៅកាន់សំណាក់យមរាជ មួយទៀតទីសំចតក្នុងចន្លោះ មិនមានដល់អ្នកទេ សូម្បីស្បៀងក៏មិនមានដល់អ្នក ។

អ្នកចូរធ្វើទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឱ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក (ធ្វើយ៉ាងនេះហើយ) នឹងទៅជាអ្នកកម្ចាត់បង់មន្ទិលបាន មិនមានទីទួលគឺកិលេស និងមិនត្រូវចូលទៅកាន់ជាតិ ជរា ព្យាធិ មរណៈ ទៀតឡើយ ។

# កំណាព្យបទពាក្យ ៨

ឥឡូវខ្លួនអ្នកប្រែគ្រប់អន្លើ

ប្រៀបដូចស្លឹកឈើទុំជិតជ្រុះហើយ

ស្បៀងគឺកុសលក៏មិនមានឡើយ

ចូរកុំកន្តើយឆាប់រកទីពឹង ។

ទាំងពួកបុរសរបស់យមរាជ

ពេញដោយអំណាចគ្មានអ្វីទទឹង

នាំយកអ្នកទៅមិនអាចមុខរឹង

ប្រកែកខំប្រឹងអង្វរពន្យា ។

ឥឡូវអ្នកនៅក្នុងក្តីវិនាស

ត្រូវស្រូតរវាសធ្វើបុណ្យនានា

ព្រោះអ្នកកំពុងតែត្រូវជរា

កៀងចូលមាគ៌ានៃដែនមរណៈ ។

ចូរអ្នកព្យាយាមឱ្យឆាប់កុំខ្លាច

ចូរជាអ្នកប្រាជ្ញរួចពីវដ្តៈ

រួចជាតិជរាព្យាធិមរណៈ

ភូមិព្រះអរិយៈទទួលអ្នកបាន ។

ពេលអ្នកលែងមានទូលគឺកិលេស

បាបចាញ់ចំណេះឈប់ហ៊ានរំខាន

ពីព្រោះមន្ទិលក្នុងចិត្តប៉ុន្មាន

អ្នកលះរុញច្រានលាងបានល្អហើយ ។

ដោយឧបាសិកា *ឌិម លក្ខណា*

# គាថាទី ២៣

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រាហ្មណ៍ម្នាក់ ទើបត្រាស់នូវព្រះគាថានេះថា

**អនុបុព្វេន មេធាវី ថោកំ ថោកំ ខណេ ខណេ**

**កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។**

អ្នកមានប្រាជ្ញា គួរកម្ចាត់បង់មន្ទិលរបស់ខ្លួនបន្តិចម្តង ៗ រាល់ ៗ ខណៈ ដោយលំដាប់ ដូចជាងមាសជំរះស្នឹម ឬច្រែះរបស់មាសដូច្នោះ ។

# កំណាព្យបទកាកគតិ

អ្នកមានប្រាជ្ញា  គួរតែប្រហារ  បង់ចោលមន្ទិល
ដែលមានក្នុងខ្លួន  ឧស្សាហ៍មិនខ្ជិល ឱ្យសឹកកិរិចរិល
ដោយមិនប្រហែស ។

ដូចជាជាងមាស ខិតខំជម្រះ  នូវស្នឹមឬច្រែះ
ដែលជាប់នឹងមាស ឱ្យបានភ្លឺថែស ប្រយ័ត្នមិនធ្វេស
វែងបានផលល្អ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២៤

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវព្រះតិស្សត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**អយសា វ មលំ សមុដ្ឋិតំ**

**តទុដ្ឋាយ តមេវ ខាទតិ**

**ឯវំ អតិធោនចារិនំ**

**សានិ កម្មានិ នយន្តិ ទុគ្គតឹ ។**

ច្រែះកើតអំពីដែក លុះកើតអំពីដែកនោះហើយ តែងស៊ីដែកនោះវិញ យ៉ាងណាមិញ កម្មទាំងឡាយរបស់ខ្លួន តែងនាំបុគ្គលអ្នកប្រព្រឹត្តកន្លងបញ្ញាជាគ្រឿងជម្រះចិត្ត ឱ្យទៅកាន់ទុគ្គតិ ក៏យ៉ាងនោះឯង ។

# កំណាព្យបទពាក្យ ៧

ថាបើច្រែះកើតពីដែកណា តែងតែទំពាស៊ីដែកនោះ

ឱ្យតូចឱ្យស្តើងឬឱ្យធ្លុះ ឱ្យរលាយអស់គ្មានសល់អ្វី ។

នេះដូចជាបាបគ្រប់អន្លើ ដែលសត្វបានធ្វើក្នុងលោកីយ៍

តែងនាំអ្នកធ្វើទាំងប្រុសស្រី ឱ្យទៅអវចីយ៉ាងនោះឯង ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២៥

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវលោលុទាយិត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា**
**មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ ។**

មន្តទាំងឡាយមានការមិនស្វាធ្យាយន៍ ជាមន្ទិល ផ្ទះទាំងឡាយមានការមិនថែទាំ ជាមន្ទិល សេចក្តីខ្ជិល ជាមន្ទិលរបស់ពណ៌សម្បុរ សេចក្តីប្រមាទ ជាមន្ទិលរបស់បុគ្គលអ្នករក្សា ។

# កំណាព្យប្រែធភាគតិ

មន្តផងទាំងឡាយ តែងអន្តរាយ ភ្លាត់ខុសលំអាន
ចំពោះអ្នកណា មិនសូវធ្លាប់បាន ស្វាធ្យាយនីសូត្រអាន
ឱ្យបានទៀងទាត់ ។

ការមិនឧស្សាហ៍ ដុសខាត់កាយា ឱ្យល្អហ្មត់ចត់
នោះជាមន្ទិល នៃស្បែកប្រាកដ សម្បុរក៏អត់
មានភាពភ្លឺថ្លា ។

សេចក្តីប្រមាទ មិនខំសង្វាត នូវរាល់កិច្ចការ
គឺជាមន្ទិល នៃអ្នករក្សា មិនគ្រប់គ្រងទ្វារ
ដោយស្មារតី ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២៦

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវកុលបុត្រម្នាក់ ទើបត្រាស់នូវព្រះគាថានេះថា

**មលិត្ថិយា ទុច្ចរិតំ មច្ឆេរំ ទទតោ មលំ**
**មលា វេ បាបកា ធម្មា អស្មឹ លោកេ បរម្ហិ ច**
**តតោ មលា មលតរំ អវិជ្ជា បរមំ មលំ**
**ឯតំ មលំ បហន្ត្វាន និម្មលា ហោថ ភិក្ខវោ ។**

ការប្រព្រឹត្តអាក្រក់ (ការក្បត់ចិត្តប្តី) ជាមន្ទិលរបស់ស្ត្រី សេចក្តីកំណាញ់ ជាមន្ទិលរបស់អ្នកឱ្យ ធម៌អាក្រក់ទាំងឡាយ ជាមន្ទិលក្នុងលោកនេះ និងលោកខាងមុខ ធម្មជាតជាមន្ទិលដ៏លើសលប់ ជាងមន្ទិលទាំងនោះ គឺអវិជ្ជា ជាមន្ទិលដ៏ក្រៃលែង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះមន្ទិលទាំងនេះចេញ ចូរកុំជាអ្នកមានមន្ទិលឡើយ ។

# កំណាព្យបទពាក្យ ៨

ផិតក្បត់ភស្តាប្រព្រឹត្តអាក្រក់

ជាធម៌កខ្វក់នាំធ្លាក់អវចី

និងជាមន្ទិលរបស់ស្ត្រី

ដឹងហើយកុំបីមានក្តីប្រមាទ ។

វិភាពកំណាញ់ក៏ជាមន្ទិល

នៃជនល្ងង់ខ្លិលមិនប្រឹងសង្វាត

ធ្វើបុណ្យធ្វើទានសន្សំចិត្តឆ្លាត

ខ្លាចអស់ខ្លាចខាតព្រោះមច្ឆរិយៈ ។

ចំណែកឯធម៌អាក្រក់ទាំងឡាយ

ដែលយើងខ្វល់ខ្វាយទទួលរាក់ទាក់

ក៏ជាមន្ទិលក្នុងលោកនេះជាក់

ព្រមទាំងបរលោកឯនាយផង ។

ប៉ុន្តែធម្មជាតិដែលជាមន្ទិល

នាំយើងឱ្យវិលជាប់ក្នុងចំណង

គឺអវិជ្ជាជាគ្រឿងសៅហ្មង

លើសលប់ចម្បងជាងអ្វីទាំងអស់ ។

ភិក្ខុទាំងឡាយចូរអ្នកលះចេញ

មន្ទិលនោះមិញកុំស្តាយស្រណោះ

កុំជាអ្នកមានមន្ទិលឱ្យសោះ

នេះហើយផ្លូវរស់នៃពុទ្ធសាសនា ។

ដោយឧបាសិកា ***ឌិម លក្ខណា***

# គាថាទី ២៧

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវសទ្ធិវិហារិកនៃព្រះសារីបុត្រឈ្មោះចូឡសារី ទើបត្រាស់នូវព្រះគាថានេះថា

**សុជីវំ អហិរិកេន    កាកសូរេន ធំសិនា**
**បក្ខន្ទិនា បគព្ភេន    សង្កិលិដ្ឋេន ជីវិតំ ។**
**ហិរីមតា ច ទុជ្ជីវំ    និច្ចំ សុចិគវេសិនា**
**អលីនេនាបគព្ភេន    សុទ្ធាជីវេន បស្សតា ។**

បុគ្គលអ្នកមិនមានសេចក្តីអៀនខ្មាស ក្លៀវក្លា ដូចសត្វក្អែក កំចាត់បង់គុណរបស់អ្នកដទៃ ជាអ្នកឈ្លានពាន (យកមុខ) ជាអ្នកឃ្មើសឃ្មង ជាមនុស្សសៅហ្មង រស់នៅដោយងាយ ។

ចំណែកបុគ្គលអ្នកមានសេចក្តីអៀនខ្មាស ស្វែងរកអំពើស្អាតជានិច្ច មិនឡេះឡោះមិនឃ្មើសឃ្មង រស់នៅដោយកម្មដ៏បរិសុទ្ធ អ្នកឃើញត្រូវ រស់នៅដោយលំបាក ។

# កំណាព្យបទកាកគតិ

អ្នកឥតអៀនខ្មាស តែងក្លៀវក្លាណាស់  ដូចជាសត្វក្អែក
ហ៊ានធ្វើគ្រប់យ៉ាង ឱ្យតែបានប្លែក  មិនខ្លាចទាស់ភ្នែក
សប្បុរសនានា ។

ជាមនុស្សឃ្នើសឃ្នង មានចិត្តសៅហ្មង លុបគុណពានពារ
ចិញ្ចឹមជីវិត  ដោយអនេសនា  សម្បូរលាភា
រស់នៅដោយងាយ ។

ឯអ្នកខ្មាសបាប  តែងមានសភាព  លំបាកផ្លូវកាយ
ក្នុងការស្វែងរក បច្ច័យទាំងឡាយ  ផ្លូវមិនទូលាយ
សម្រាប់រស់ឡើយ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២៨

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវឧបាសកទាំងឡាយ ៥ នាក់ ទើបត្រាស់នូវព្រះគាថានេះថា

**យោ បាណមតិមាបេតិ មុសាវាទញ្ច ភាសតិ**

**លោកេ អទិន្នំ អាទិយតិ បរទារញ្ច គច្ឆតិ**

**សុរាមេរយបានញ្ច យោ នរោ អនុយុញ្ជតិ**

**ឥធេវមេសោ លោកស្មឹ មូលំ ខណតិ អត្តនោ ។**

**ឯវំ ភោ បុរិស ជានាហិ បាបធម្មា អសញ្ញតា**

**មា តំ លោភោ អធម្មោ ច ចិរំ ទុក្ខាយ រន្ធយុំ ។**

ជនណាសម្លាប់សត្វផង និយាយពាក្យកុហកផង កាន់យកវត្ថុដែលគេមិនបានឱ្យក្នុងលោកផង សេពប្រពន្ធរបស់អ្នកដទៃផង ជនណាផឹកទឹកសុរានិងមេរ័យផង ជននោះឯងឈ្មោះថា គាស់រំលើងឫសគល់របស់ខ្លួន ក្នុលោកនេះដោយពិត ។

ម្នាលបុរសដ៏ចម្រើន អ្នកចូរដឹងយ៉ាងនេះថា ជនទាំងឡាយមានធម៌ដ៏លាមក រមែងមិនជាអ្នកសង្រួមដូច្នេះ លោភៈនិងសភាពមិនមែនធម៌គឺទោសៈ ចូរកុំបៀតបៀនអ្នក ឱ្យបានសេចក្ដីទុក្ខអស់កាលយូរឡើយ ។

# កំណាព្យបទពាក្យ ៧

បុគ្គលណាមួយសម្លាប់សត្វ  ឱ្យគេខ្ចាត់ព្រាត់អស់សង្ខារ
លួចយកនូវទ្រព្យជននានា    ឬសេពភរិយាអ្នកដទៃ ។
និយាយតែពាក្យកោងមុសា  ការពិតបែរជារឿងបំភ្លៃ
ឬផឹកសុរានិងមេរ័យ    បំផ្លាញស្មារតីឱ្យវក់វី ។
ជននោះឈ្មោះថាជីករំលើង  ខ្លួនឯងឱ្យប៉ើងចាកលោកីយ៍
ជាមនុស្សរស់នៅមិនប្រពៃ ហាក់ដូចជាក្ស័យជន្មទាំងស្រស់ ។
នៃវើយបុរសចូររស់នៅ    ឱ្យរួចរណ្តៅបាបទាំងអស់
លោភៈទោសៈកុំមានសោះ  ចូរកុំមានគ្រោះអស់កាលយូរ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ២៩

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវភិក្ខុកំលោះឈ្មោះតិស្សៈ ទើបត្រាស់នូវព្រះគាថានេះថា

**ទទាតិ វេ យថាសទ្ធំ យថាបសាទនំ ជនោ**
**តត្ថ យោ មង្កុតោ ហោតិ បរេសំ បានភោជនេ**
**ន សោ ទិវា វា រត្តឹ វា សមាធឹ អធិគច្ឆតិ ។**
**យស្ស ចេតំ សមុច្ឆិន្នំ មូលឃច្ចំ សមូហតំ**
**ស វេ ទិវា វា រត្តឹ វា សមាធឹ អធិគច្ឆតិ ។**

ជនរមែងឱ្យតាមសទ្ធា តាមសេចក្ដីជ្រះថ្លា បុគ្គលណា ជាអ្នកអៀនខ្នាសក្នុងទឹកនិងភោជនរបស់ជនទាំងឡាយដទៃ ជននោះរមែងមិនបានសមាធិចិត្ត ក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ឡើយ ។

លុះតែសេចក្ដីអៀនខ្នាសនោះ បុគ្គលណា បានផ្ដាច់ផ្ដិលដកឡើង ធ្វើឱ្យមានឫសគល់ដាច់ហើយ បុគ្គលនោះឯង ទើបបានសមាធិចិត្ត ក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ ។

# កំណាព្យបទកាកគតិ

វីអ្នកឱ្យទាន គេឱ្យតាមមាន តាមការជ្រះថ្លា
បើអ្នកទទួល ខ្វះអប្បិច្ឆា តែងមានចិន្តា
ខ្មាសអៀនអ្នកផង ។
ចិត្តបុគ្គលនោះ មិនអាចជម្រុះ អស់ភាពសៅហ្មង
សមាធិចិត្ត ចេះតែរំលង យប់ថ្ងៃកន្លង
គ្មានការចម្រើន ។
បើមិនខ្មាសអៀន ចំពោះការបាន វត្ថុតិចច្រើន
សមាធិចិត្ត ពិតជាចម្រើន ក្តីសុខកើតកើន
ទាំងយប់ទាំងថ្ងៃ ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ៣០

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវឧបាសកទាំងឡាយ ៥ នាក់ ទើបត្រាស់នូវព្រះគាថានេះថា

**នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ គហោ**
**នត្ថិ មោហសមំ ជាលំ នត្ថិ តណ្ហាសមា នទី ។**

ភ្លើងស្មើដោយរាគៈ មិនមាន ការចាប់ស្មើដោយទោសៈ មិនមាន បណ្តាញស្មើដោយមោហៈ មិនមាន ស្ទឹងស្មើដោយតណ្ហា មិនមាន ។

# កំណាព្យបទព្រហ្មគីតិ

ភ្លើងក្តៅស្មើរាគៈ ក្នុងលោកជាក់រកមិនបាន
រាគៈឆេះសព្វឋាន ដល់និព្វានទើបសុខា ។
ការចាប់គ្រប់អ្វី ៗ ដែលអប្រិយគួររអារ
ស្មើទោសៈហីនា ក្នុងលោកាពិតមិនមាន ។
បណ្តាញដែលជំពាក់ ស្មើមោហៈក្នុងសន្តាន
សម្តេចព្រះទ្រង់ញាណ ត្រាស់ថាគ្មានក្នុងលោកា ។
វិស្ទឹងផងទាំងឡាយ ហូរបានឆ្ងាយសព្វទិសា
ឆ្លងកាត់ភពនានា ស្មើតណ្ហាពិតមិនមាន ។

*ដោយ ភិក្ខុ វជិរប្បញ្ញោ* ***ស.ស.ជ.***

# គាថាទី ៣១

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងព្រៃឈើផ្ចង់ ដែលអាស្រ័យនឹងនគរភទ្ទិយៈ ទ្រង់ប្រារព្ធនូវមេណ្ឌកសេដ្ឋី ទើបត្រាស់នូវព្រះគាថានេះថា

**សុទស្សំ វជ្ជមញ្ញេសំ អត្តនោ បន ទុទ្ទសំ**
**បរេសំ ហិ សោ វជ្ជានិ ឱបុនាតិ យថាភុសំ**
**អត្តនោ បន ឆាទេតិ កលិំវ កិតវា សឋោ ។**

ទោសរបស់ពួកជនដទៃ ឃើញបានដោយងាយ ចំណែកទោសរបស់ខ្លួន ឃើញបានដោយលំបាក ព្រោះថាបុគ្គលនោះ រោយទោសទាំងឡាយ ចំពោះ

ពួកជនដទៃ ដូចបុគ្គលរោយអង្កាមដូច្នោះ តែថា រមែង បិទបាំងទោសរបស់ខ្លួនទុក ដូចព្រានបក្សីបិទបាំង អត្តភាព ដោយវត្ថុសម្រាប់បិទបាំង (មានមែកឈើ ជាដើម) ដូច្នោះ ។

# កំណាព្យបទពាក្យ៧

ទោសរបស់ពួកជនដទៃ

រវាសរវៃមើលឃើញភ្លាម

ឯទោសខ្លួនឯងតែងព្យាយាម

បិទបាំងលាក់លៀមពុំមានស្រាក ។

ទោសគេឆាប់ឃើញហួសប្រមាណ

ទោសខ្លួនឃើញបានដោយលំបាក

ព្រោះចិត្តបុគ្គលនោះតោកយ៉ាក

រោយទោសប្រឡាក់អ្នកដទៃ ។

ប្រៀបដូចបុគ្គលរោយអង្កាម

ហើយបិទបាំងស្នាមជាប្រក្រតី

លាក់ទោសខ្លួនដូចព្រានបក្សី

ពេលចង់ប្រល័យសត្វនានា ។
គេតុបតែងខ្លួនគ្រប់អន្លើ
បាំងដោយមែកឈើធ្វើដូចជា
មិនមែនជាព្រានមានចិត្តមារ
ចាំប្រុងប្រហារសត្វនោះឡើយ ។

ដោយឧបាសិកា *ឱម លក្ខណា*

# គាថាទី ៣២

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវឧជ្ឈានសញ្ញិត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**បរវជ្ជានុបស្សិស្ស និច្ចំ ឧជ្ឈានសញ្ញិនោ**
**អាសវា តស្ស វឌ្ឍន្តិ អារា សោ អាសវក្ខយា ។**

កាលបុគ្គលគយឃ្លាំមើលទោស របស់បុគ្គលដទៃ ជាប្រក្រតី មានការសម្គាល់ហេតុក្នុងការពោលទោស (អ្នកដទៃ) ជានិច្ចជាប្រក្រតី អាសវៈទាំងឡាយ របស់បុគ្គលនោះ តែងចំរើន បុគ្គលនោះឈ្មោះថា ឋិតនៅឆ្ងាយអំពីធមិជាគ្រឿងអស់អាសវៈ ។

# កំណាព្យបទពាក្យ ៧

បុគ្គលកាលគយឃ្លាំមើលទោស

ចាំចាប់កំហុសអ្នកដទៃ

កត់ហេតុពោលឡើងជាប្រក្រតី

អាសវៈចាស់ថ្មីនៃជននោះ ។

តែងតែចម្រើនគ្រប់វេលា

កើតទាំងកម្មពៀរឥតរំលោះ ។

បើមិនប្រឹងលះចៀសបាបគ្រោះ

បានឈ្មោះថាឆ្ងាយពីនិព្វាន ។

ដោយឧបាសិកា *ឱម លក្ខណា*

# គាថាទី ៣៣

សម័យមួយ ព្រះមានព្រះភាគទ្រង់ផ្ទំលើគ្រែតូចជាទីបរិនិព្វាន ក្នុងព្រៃសាលវ័ន នានគរកុសិនារា ទ្រង់ប្រារព្ធនូវសុភទ្ទបរិព្វាជក ទើបត្រាស់នូវព្រះគាថានេះថា

អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរេ
បបញ្ចាភិរតា បជា និប្បបញ្ចា តថាគតា ។
អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរេ
សង្ខារា សស្សតា នត្ថិ នត្ថិ ពុទ្ធានមិញ្ជិតំ ។

ស្នាមជើងក្នុងអាកាស មិនមាន សមណៈខាងក្រៅ មិនមាន ពួកសត្វត្រេកអរហើយ ក្នុងធម៌ជាគ្រឿងយឺតយូរ ព្រះតថាគតទាំងឡាយ មិនមានធម៌ជាគ្រឿងយឺតយូរឡើយ ។

ស្នាមជើងក្នុងអាកាស មិនមាន សមណៈខាងក្រៅ មិនមាន សង្ខារទាំងឡាយជារបស់ទៀងមិនមាន ព្រះពុទ្ធទាំងឡាយមិនមានកិលេស ជាគ្រឿងញាប់ញ័រទេ ។

# កំណាព្យបទពាក្យ ៧

មិនមានស្នាមជើងក្នុងអាកាស

ព្រះពុទ្ធបានត្រាស់ឆ្លើយសំនួរ

បបញ្ចធម៌គ្រឿងឃឺតយូរ

ក៏បរមគ្រូលះអស់ហើយ ។

សមណៈខាងក្រៅពុទ្ធសាសនា

ព្រះអង្គត្រាស់ថាពុំមានឡើយ

សង្ខារដែលទៀងឃ្លាងពីត្រើយ

ក៏គ្មានសោះឡើយក្នុងភពត្រៃ ។

ធម៌ណាសៅហ្មងនាំពន្យា

សត្វលោកច្រើនគ្នាត្រេកអរក្រៃ

រាប់អានសេពគប់ទាំងយប់ថ្ងៃ

តែព្រះពុទ្ធថ្លៃទ្រង់ផ្ដាច់បង់ ។

លះគ្រប់ឫសគល់នៃតណ្ហា

ព្រះទ័យប្រាថ្នាជួយស្រោចស្រង់

សត្វលោកដែលនៅជាប់ចំណង

ឱ្យផុតរបងសង្សារវដ្ដ ។

ដោយឧបាសិកា *ខិម លក្ខណា*

# គាថាទី ៣៤[១]

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវមហាមាត្យអ្នកវិនិច្ឆ័យទាំងឡាយ ទើបត្រាស់នូវព្រះគាថានេះថា

**ន តេន ហោតិ ធម្មដ្ឋោ យេនត្ថំ សហសា នយេ**

**យោ ច អត្ថំ អនត្ថញ្ច ឧភោ និច្ឆេយ្យ បណ្ឌិតោ។**

**អសាហសេន ធម្មេន សមេន នយតី បរេ**

**ធម្មស្ស គុត្តោ មេធាវី ធម្មដ្ឋោតិ បវុច្ចតិ ។**

---

១-បើរាប់តាមលំដាប់ក្នុងធម្មដ្ឋវគ្គ ត្រូវជាគាថា ទី ១

បុគ្គលកាត់សេចក្តីដោយអាក្រក់ ដោយសារហេតុណា ឈ្មោះថាជាអ្នកតាំងនៅក្នុងធម៌ ដោយហេតុនោះ មិនទាន់បានទេ លុះត្រាតែបុគ្គលណា ជាបណ្ឌិតកាត់សេចក្តីទាំងពីរ គឺសេចក្តីពិត និងសេចក្តីមិនពិតណែនាំជនទាំងឡាយដទៃ ដោយមិនអាក្រក់ ដោយសារធម៌តាមសមគួរ (ដល់ទោស) បុគ្គលនោះឈ្មោះថាជាអ្នកមានប្រាជ្ញារក្សាធម៌ ទើបហៅថាអ្នកតាំងនៅក្នុងធម៌ ។

# កំណាព្យបទពាក្យ ៧

បុគ្គលកាត់ក្តីដោយអាក្រក់

លំអៀងខ្មៅល្អក់ព្រោះហេតុណា

ជននោះមិនទាន់បានឈ្មោះថា

អ្នកមានប្រាជ្ញាក្នុងធម៌ទេ ។

លុះត្រាបុគ្គលជាបណ្ឌិត

កាត់ក្តីសុចរិតឥតវៀចវេរ

ទៅតាមសាច់រឿងមិនងាករេ

មិនប្តូរបំបែរខុសសច្ចះ ។

ជននោះទើបជាបុគ្គលល្អ

តាំងនៅក្នុងធម៌មិនប្រឡាក់

ដោយយសដោយលាភសក្ការៈ

ព្រោះឆ្ងាយវដ្ដៈឈ្មោះអ្នកប្រាជ្ញ ។

ដោយឧបាសិកា *ឱម លក្ខណា*

# ធម្មជាតិកើតរលត់

ត្រចៀកច្រមុះអណ្ដាតកាយ

និងភ្នែកទាំងឡាយមានលក្ខណៈ

នៅត្រង់ប៉ះខ្ទប់នឹងភាវៈ

ដែលតែងស្មោះស្ម័គ្រជាគូគ្នា ។

គឺភ្នែកតែងប៉ះខ្ទប់នឹងរូប

ត្រចៀកតែងស្រូបសូរនានា

ច្រមុះហិតក្លិនមិនមុសា

អណ្ដាតធានាភ្លក្សដឹងរស ។

វីកាយប៉ះនឹងផោដ្ឋព្វៈ

ជាសភាវៈ ធម៌ជាន់ខ្ពស់

ប៉ះហើយកន្លងព្រះទ្រង់យស

បានប្រទានឈ្មោះកើតរលត់ ។

ដោយឧបាសិកា *ឱម លក្ខណា*

# ពិចារណាហេតុផល

បើមានស្រឡាញ់ត្រូវមានស្អប់

បើមានគួរគាប់ត្រូវមានខុស

បើមានត្រចៀកភ្នែកច្រមុះ

ត្រូវតែសន្ដោសកាត់បន្ថយ ។

កុំយល់ថាខ្លួនជាអ្នកខឹង

អ្នកឃើញឮដឹងប្រឹងបណ្ដោយ

សម្មាទិដ្ឋិឱ្យចុះខ្សោយ

ថាខ្លួននេះហើយគឺម្ចាស់ការ ។

តាមពិតមនុស្សយើងជាមនុស្សយន្ត

ដែលហេតុពីមុនបានរចនា

ទោះបានជួបអ្វីខុសប្រាថ្នា

ត្រូវជឿជាក់ថានេះកម្មផល ។

ដោយឧបាសិកា *ឱម លក្ខណា*

# ថាមិនមែនរូបដដែលទេ!

ថ្ងៃខែចេះតែកន្លងទៅ

រូបកាយមិននៅក្មេងទៀតឡើយ

សាច់ជ្រួញខ្នងកោងសក់ស្កូវហើយ

រោគក៏មិនស្បើយកើតដេរដាស ។

បើគិតមិនដល់យល់ច្រឡំ

ថាតូចទៅធំក្មេងទៅចាស់

ជារូបតែមួយគ្មានប្តូរផ្លាស់

តាមពិតព្រះត្រាស់ធម៌សច្ចៈ ។

ថារូបកើតស្លាប់បន្តគ្នា

ផ្លាស់ប្តូរគ្រប់គ្រាលឿនឥតអាក់

ភ្នែកគ្មានបញ្ញាប្រៀបដូចខ្វាក់

មិនឃើញសច្ចៈធម៌អនិច្ចំ ។

ស្លាប់កើតទាំងរស់រាប់ពុំបាន

តែមិននឹកស្មានថាមានខ្ទាំង

